**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ៤២៨៨.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតនិងការតែងតាំងសមាសភាព
## ក្រុមប្រឹក្សាភិបាលនៃបណ្ឌិត្យសភានគរបាលកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាភិបាលនៃបណ្ឌិត្យសភានគរបាលកម្ពុជា ដែលហៅកាត់ថា "ក.ប.ន.ក." ដើម្បីដឹកនាំ និងតម្រង់ទិសការងារដល់បណ្ឌិត្យសភានគរបាលកម្ពុជា ក្នុងការងារបណ្តុះបណ្តាលមន្ត្រីនគរបាលនិងមន្ត្រីពន្ធនាគារ ការងារស្រាវជ្រាវ និងការងារពាក់ព័ន្ធផ្សេងទៀត។

**ប្រការ២.-**

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃបណ្ឌិត្យសភានគរបាលកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តមអភិសន្តិបណ្ឌិត | **ស សុខា** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២. ឯកឧត្តមបណ្ឌិត | **ឌួច ទីសាឈសុខ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម | **អ៊ី ចន្ទ្ធា** | អនុរដ្ឋលេខាធិការ និងជានាយករង ខុទ្ទកាល័យប្រចាំការ | អនុប្រធាន |
| ៤. ឯកឧត្តមនាយឧត្តមសេនីយ៍ | **ស ថេត** | អគ្គស្នងការនគរបាលជាតិ | អនុប្រធាន |
| ៥. ឯកឧត្តមនាយឧត្តមសេនីយ៍ | **សេខ យុអ៊ាន់** | អគ្គនាយក នៃអគ្គនាយកដ្ឋាននិងហិរញ្ញវត្ថុ | សមាជិក |
| ៦. ឯកឧត្តមនាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ | **សេខ ផល្លី** | អគ្គនាយក នៃអគ្គនាយកដ្ឋានធនធានមនុស្ស | សមាជិក |
| ៧. ឯកឧត្តមនាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ | **ឯក ឃាវីសេខ** | ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា | សមាជិកអចិន្ត្រៃយ៍ |
| ៨. ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យ | **ថ្នាក់ ណារ៉ុង** | អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា និងជាប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍គ្រូនគរបាលជាតិ ជាតំណាងសាស្ត្រាចារ្យ | សមាជិក |
| ៩. ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យ | **ទ៉េខ សុធី** | អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍គ្រូនគរបាលជាតិ ជាតំណាងសាស្ត្រាចារ្យ | សមាជិក |
| ១០. លោកស្រី | **ឈឹម ប៉័ខហួន** | ជំនួយការ ឯកឧត្តមអភិសន្តិបណ្ឌិត | លេខាធិការ |

**ប្រការ៣.-**

ក.ប.ន.ក មានសិទ្ធិអំណាច និងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យនិងអនុម័តផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍ ផែនការសកម្មភាព គម្រោងថវិកា និងគម្រោងលទ្ធកម្មប្រចាំឆ្នាំរបស់ ប.ន.ក
- ពិនិត្យនិងអនុម័តផែនការបណ្តុះបណ្តាល និងផែនការស្រាវជ្រាវរបស់ ប.ន.ក
- ពិនិត្យ វាយតម្លៃ និងអនុម័តលើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំរបស់ ប.ន.ក
- ពិនិត្យនិងអនុម័តលើសំណើរបស់ប្រធាន ប.ន.ក ក្នុងការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងរបស់ ប.ន.ក
- ពិនិត្យនិងអនុម័តលើផែនការថ្មីរបស់ប្រធាន ប.ន.ក ពាក់ព័ន្ធនឹងការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗដល់ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ គ្រូបង្រៀន និងមន្ត្រីនៃ ប.ន.ក
- បំពេញកិច្ចការផ្សេងទៀតដែលចាំបាច់ ដើម្បីសម្រេចមុខងារ និងភារកិច្ចរបស់ ប.ន.ក។

**ប្រការ៤.-**

ក.ប.ន.ក មានរបបប្រជុំសាមញ្ញប្រចាំត្រីមាស។ ក្នុងករណីចាំបាច់ ក.ប.ន.ក អាចប្រជុំវិសាមញ្ញតាមការស្នើសុំពីសមាជិក ក.ប.ន.ក ចំនួន២ភាគ៣ ឬតាមការកោះអញ្ជើញរបស់ប្រធាន ក.ប.ន.ក។

សេចក្តីសម្រេចរបស់ក.ប.ន.ក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខារបស់ប្រធាន និងរក្សាទុកនៅទីស្នាក់ការរបស់ប.ន.ក។

កិច្ចប្រជុំក.ប.ន.ក ត្រូវកត់ត្រាក្នុងកំណត់ហេតុ ដែលមានលេខាធិការជាអ្នករៀបចំសេចក្តីព្រាងកំណត់ហេតុ ជូនសមាជិកក្រុមប្រឹក្សាភិបាល ក្រោយចប់កិច្ចប្រជុំ។

**ប្រការ៥.-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ២ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ[illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ កញ្ញា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល ៖**

- ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ